ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

មន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ

ខេត្តសៀមរាប

លេខ......៦៤១............ម.ក.ប

## ប្រធាន មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
## សូមជំរាបមក
## លោកនាយក សណ្ឋាគារអង្គរសេនជូរី

**កម្មវត្ថុ ៖** ការអនុញ្ញាតិឲ្យប្រើប្រាស់បញ្ជីបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រ។

**យោង ៖** លិខិតរបស់លោកលេខ(គ្មាន) ចុះថ្ងៃទី ០២ខែ តុលា ឆ្នាំ២០១៤។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបលោកជ្រាបថា មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមិនយល់ទាស់ទេ ចំពោះការប្រើប្រាស់បញ្ជីបើកប្រាក់ឈ្នួលតាមប្រព័ន្ធកុំព្យូទ័រដូចដែល លោកនាយកមានបញ្ជីគំរូភ្ជាប់មកជាមួយលិខិតរបស់លោកនោះ។

ម្យ៉ាងទៀតដើម្បីឲ្យបានសមស្របតាមច្បាប់ស្តីពីការងារនិងដើម្បីងាយស្រួលដល់ក្រុមអធិការកិច្ចការងារធ្វើការត្រួតពិនិត្យក្នុងករណីចាំបាច់ខ្ញុំសូមលោករក្សាបញ្ជីបើកប្រាក់ឈ្នួលនេះ ទុកជាឯកសារក្នុងរយៈពេលបី (០៣) ឆ្នាំ បន្ទាប់ពីថ្ងៃបើកប្រាក់ឈ្នួល ខែនីមួយៗ។

ក្នុងក្តីសង្ឃឹមថា លោកនាយក នឹងអនុវត្តតាមការណែនាំខាងលើ បានត្រឹមត្រូវជាមិនខាន។

សូមលោកទទួលនូវសេចក្តីគោរពរាប់អានដ៏ស្មោះស្ម័គ្រ អំពីខ្ញុំ ៕

សៀមរាប ថ្ងៃទី១៦ ខែ តុលា ឆ្នាំ២០១៤

**ប្រធានមន្ទីរ**

**ច័ន្ទ សុខុមចិត្តា**